Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយបន្ទាន់

# កាលបរិច្ឆេទដំណើរការពិគ្រោះយោបល់ជាមុន សម្រាប់គម្រោងទំនប់វារីអគ្គិសនីប៉ាក់ឡាយ (Pak Lay) ត្រូវបានកំណត់

**ក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៨** – ក្រុមការងារនៃគណៈកម្មាធិការចម្រុះ សម្រាប់នីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (ហៅកាត់ថា PNPCA) របស់គណៈកម្មការទន្លេមេគង្គ បានឯកភាពគ្នាលើកាលបរិច្ឆេទចាប់ផ្តើមអនុវត្តដំណើរការពិគ្រោះយោបល់ជាមុនរយៈពេល ៦ ខែ នៃគម្រោងទំនប់វារីអគ្គិសនីប៉ាក់ឡាយ ដែលមានសមត្ថភាពផលិតអគ្គិសនី ៧៧០ មេហ្គាវ៉ាត់ ដែលត្រូវបានលើកស្នើឡើងលើដងទន្លេមេគង្គមេក្នុងប្រទេសឡាវ។

ក្រុមការងារនៃគណៈកម្មាធិការចម្រុះ ដែលមានសមាជិកជាតំណាងបច្ចេកទេសជាន់ខ្ពស់មកពីប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម និងដែលបំពេញតួនាទីជាស្ថាប័នផ្តល់ប្រឹក្សាដល់គណៈកម្មាធិការចម្រុះរបស់ MRC ក្នុងការអនុវត្តនីតិវិធី PNPCA បានប្រកាសពីការសម្រេចចិត្តនេះ បន្ទាប់ពីបានជជែកពិភាក្សាគ្នាយ៉ាងល្អិតល្អន់អំពីដំណើរការនេះ ក្នុងអំឡុងកិច្ចប្រជុំដំបូងរបស់ខ្លួន ដែលត្រូវបានបញ្ចប់កាលពីថ្ងៃទី ៨ ខែ សីហា ក្នុងទីក្រុងវៀងចន្ទ។ ក្រុមការងារបានកំណត់ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៨ ជាកាលបរិច្ឆេទ សម្រាប់ចាប់ផ្តើមដំណើរការនេះ។

លោក តៃ ណាវុធ ប្រធានក្រុមការងារនៃគណៈកម្មាធិការចម្រុះ មានប្រសាសន៍ថា "កិច្ចពិគ្រោះយោបល់ជាមុននេះ នឹងផ្តល់ឱ្យប្រទេសដែលទទួលបានការជូនដំណឹង សហគមន៍ដែលរងផលប៉ះពាល់ និងតួអង្គពាក់ព័ន្ធដទៃទៀត នូវឱកាសពិនិត្យឡើងវិញលើគម្រោង និងលើកឡើងពីការព្រួយបារម្ភសមស្របរបស់ពួកគេ អំពីផលប៉ះពាល់អវិជ្ជមានឆ្លងដែន លើបរិស្ថាននិងប្រជាពលរដ្ឋ។ កិច្ចពិគ្រោះយោបល់ជាមុននេះ ក៏ផ្តល់លទ្ធភាពឱ្យប្រទេសដែលលើកស្នើគម្រោង យល់ដឹងពីការព្រួយបារម្ភទាំងនេះកាន់តែច្បាស់ ក៏ដូចជា លើកឡើងនូវវិធានការដើម្បីឆ្លើយតបចំពោះការព្រួយបារម្ភទាំងនេះផងដែរ"។

ក្រុមការងារនៃគណៈកម្មាធិការចម្រុះនេះ ក៏បានពិភាក្សាលើសំណើពន្យាពេលដំណើរការពិគ្រោះយោបល់ជាមុន ដែលលើកឡើងដោយលោក ផាំ ទាន់ ផាន នាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC ផងដែរ។ ការពិភាក្សាលើសំណើពន្យាពេលនេះ ក៏ដោយសារតែការប្រកាសរបស់នាយករដ្ឋមន្ត្រីឡាវ កាលពីមួយថ្ងៃមុនកិចប្រជុំនេះ ឱ្យមានការពិនិត្យរាល់ទំនប់ទាំងអស់ និងផ្អាកការពិចារណាលើការវិនិយោគថ្មីៗលើគម្រោងវារីអគ្គសិនី ក្នុងប្រទេសឡាវ។ ប្រតិភូឡាវឯកភាពថា រដ្ឋាភិបាលឡាវនឹងផ្តល់ការបញ្ជាក់ជាផ្លូវការ ក្នុងពេលឆាប់ៗនេះ។

លោក ផាំ ទាន់ ផាន នាយកប្រតិបត្តិនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ មានប្រសាសន៍ថា "សម្រាប់ដំណើរការនៃកិច្ចពិគ្រោះយោបល់ជាមុននេះ លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ នឹងខិតខំឱ្យអស់ពីលទ្ធភាព ដើម្បីបំពេញតួនាទីរបស់ខ្លួន ដូចដែលមានចែងក្នុងនីតិវិធី PNPCA និងកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ ដើម្បីសម្របសម្រួលកិច្ចពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធនានាប្រកបដោយសុច្ឆន្ទៈ និងរៀបចំចងក្រងជាឯកសារក្នុងលក្ខណៈជាប្រព័ន្ធ ដើម្បីរក្សានូវទស្សនៈយល់ឃើញរបស់តួអង្គពាក់ព័ន្ធទាំងនេះ និងបង្ហាញពីរបៀបដែលទស្សនៈទាំងនេះ នឹងត្រូវលើកយកមកធ្វើការពិចារណាដោយស្ថាប័នអភិបាលកិច្ចនានារបស់ MRC ព្រមទាំងផ្តល់ព័ត៌មានត្រលប់ទៅឱ្យពួកគេវិញ ឱ្យបានទាន់ពេលវេលា និងប្រកបដោយតម្លាភាព"។

ក្នុងដំណើរការពិគ្រោះយោបល់ជាមុននេះ មានការរៀបចំវេទិកាអ្នកពាក់ព័ន្ធថ្នាក់តំបន់ចំនួនពីរលើក និងមានការចុះទស្សនកិច្ចដល់ទីតាំងគម្រោងប៉ាក់ឡាយ ក្នុងអំឡុងដំណើរការរយៈពេល ៦ ខែនេះ។ លើសពីនេះ ក៏នឹងមានការរៀបចំកិច្ចប្រជុំជាច្រើន ជាមួយតួអង្គពាក់ព័ន្ធនៅថ្នាក់ជាតិ ក្នុងបណ្តាប្រទេសជាសមាជិកផងដែរ ដើម្បីពិភាក្សា និងចងក្រងទុកជាឯកសារអំពីការព្រួយបារម្ភសមស្របនានា ដើម្បីផ្តល់ជាព័ត៌មានចូលទៅក្នុងដំណើរការនេះ។

កិច្ចពិគ្រោះយោបល់ជាមុននេះ គឺជាផ្នែកមួយនៃវិធាននីតិវិធីរបស់ MRC ជុំវិញកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ទឹកលើដងទន្លេមេគង្គមេ ដែលស្ថិតក្រោមនីតិវិធី PNPCA។ ក្រោមនីតិវិធីទាំងនេះ គម្រោងហេដ្ឋារចនាសម្ព័ន្ធណាមួយដែលប្រើប្រាស់ទឹកក្នុងដងទន្លេមេ ក្នុងអំឡុងរដូវប្រាំងក្នុងតំបន់អាងទន្លេតែមួយ ក៏ដូចជា ក្នុងរដូវវស្សារវាងអាងទន្លេចំនួនពីរ ត្រូវឆ្លងកាត់ដំណើរការពិគ្រោះយោបល់ជាមុន។ គម្រោងដែលត្រូវអនុវត្តនីតិវិធីទាំងនេះ រួមមាន គម្រោងអភិវឌ្ឍន៍ធារាសាស្ត្រ និងវារីអគ្គិសនីខ្នាតធំ ដែលអាចបង្កផលប៉ះពាល់គួរឱ្យកត់សម្គាល់ដល់បរិស្ថាន លំហូរទឹក និងគុណភាពនៃទឹកក្នុងដងទន្លេមេ។

នៅក្នុងដំណើរការពិគ្រោះយោបល់ជាមុននេះ ដោយមានការគាំទ្រផ្នែកបច្ចេកទេសនិងរដ្ឋបាលពីលេខាធិការដ្ឋាន MRC ប្រទេសជាសមាជិកដែលបានទទួលការជូនដំណឹង នឹងត្រូវពិនិត្យមើលទិដ្ឋភាពបច្ចេកទេសរបស់គម្រោង វាយតម្លៃលើផលប៉ះពាល់ឆ្លងដែន ដែលអាចកើតមានលើបរិស្ថាន និងជីវភាពរស់នៅរបស់សហគមន៍តាមដងទន្លេ និងលើកស្នើនូវវិធានការ ដើម្បីឆ្លើយតបចំពោះការព្រួយបារម្ភទាំងនេះ។ គោលដៅរួមរបស់ប្រទេសជាសមាជិក គឺការឯកភាពរួមគ្នាលើរបៀបបន្តពិនិត្យលើករណីរបស់គម្រោង ដែលត្រូវពិគ្រោះយោបល់នេះ។ នីតិវិធីនេះពុំមានគោលបំណងផ្តល់ការអនុម័ត ឬជំទាស់ ទៅនឹងគម្រោងដែលស្នើឡើងឡើយ។

ជាធម្មតា ដំណើរការនេះត្រូវការពេលវេលា ៦ ខែ ប៉ុន្តែអាចបន្តបន្ថែមទៀតបាន ប្រសិនបើមានការស្នើឡើងដោយគណៈកម្មការចម្រុះ (Joint Committee) ដែលមានសមាសភាពជាតំណាងមកពីប្រទេសជាសមាជិកទាំងបួន នៅកម្រិតប្រធាននាយកដ្ឋាន ដែលជាកម្រិតនៃកិច្ចពិគ្រោះយោបល់នេះ។

កាលពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៨ រដ្ឋាភិបាលឡាវ តាមរយៈគណៈកម្មាធិការជាតិទន្លេមេគង្គឡាវ បានជូនដំណឹងដល់លេខាធិការដ្ឋាន MRC អំពីបំណងរបស់ខ្លួនក្នុងការអនុវត្តដំណើរការពិគ្រោះយោបល់ជាមុនជាផ្លូវការ ស្តីពីគម្រោងវារីអគ្គិសនីប៉ាក់ឡាយ ដែលជាទំនប់លើដងទន្លេមេគង្គមេទី ៤ ដែលត្រូវបានដាក់ឱ្យឆ្លងកាត់ដំណើរការពិគ្រោះយោបល់ជាមុននេះ។

គម្រោងនេះ គឺជាគម្រោងទំនប់ដែលដំណើរការនៅលើទន្លេផ្ទាល់ មានទីតាំងនៅស្រុកប៉ាក់ឡាយ ក្នុងខេត្តស្សាយ៉ាបូរី នៅភាគពាយ័ព្យនៃប្រទេសឡាវ ដែលស្ថិតនៅខ្សែទឹកខាងក្រោមនៃស្ថានីយទំនប់វារីអគ្គិសនីស្សាយ៉ាបូរី ដែលកំពុងស្ថិតនៅក្នុងដំណើរការនៃការសាងសង់ និងស្ថិតនៅចម្ងាយ ២៤១ គីឡូម៉ែត្រ ខ្សែទឹកខាងលើនៃទីក្រុងវៀងចន្ទ។ ទំនប់នេះនឹងដំណើរការជាប់រហូតពេញមួយឆ្នាំជាមួយនឹងសមត្ថភាពផលិតថាមពលជាមធ្យមប្រចាំឆ្នាំចំនួន ៤.១២៤ GWh ជាមួយនឹងគោលបំណងចម្បង គឺដើម្បីផលិតថាមពលសម្រាប់ផ្គត់ផ្គង់ក្នុងប្រទេស។

ចំណាយវិនិយោគសរុបរបស់គម្រោងនេះ គឺប្រមាណជា ២.១៣៤ លានដុល្លារ ដោយការសាងសង់នឹងត្រូវចាប់ផ្តើមនៅក្នុងឆ្នាំ ២០២២ ហើយដំណើរការពាណិជ្ជកម្ម នឹងត្រូវចាប់ផ្តើមនៅពេលដែលការសាងសង់បញ្ចប់ក្នុងឆ្នាំ ២០២៩។ ក្រុមហ៊ុន PowerChina Resources Ltd គឺជាក្រុមហ៊ុនអភិវឌ្ឍន៍គម្រោង នេះបើតាមឯកសារជូនដំណឹងជាផ្លូវការពីប្រទេសឡាវ។

**កំណត់សម្គាល់សម្រាប់និពន្ធនាយក៖**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជា ជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍន៍តំបន់នេះ ប្រកបដោយចីរភាព។

**-ចប់-**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
លោក មាស សុភក្ក្រ
មន្ត្រីទំនាក់ទំនងជាមួយអ្នកសារព័ត៌មាន
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរសព្ទ៖ +856-21-263263 ភ្ជាប់បន្ត 4070
ទូរសព្ទដៃ៖ +856-20-92479737

###